



# ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍

## របាយការណ៍ប្រចាំឆ្នាំ២០១៨

## សារពីនាយក ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍

ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីរីករាយក្នុងការបង្ហាញរបាយការណ៍ប្រចាំឆ្នាំ ២០១៨។ របាយការណ៍នេះ បានឆ្លុះបញ្ចាំងពីតួនាទីរបស់អង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ ក្នុងការចូលរួមចំណែកជាមួយផែនការយុទ្ធសាស្ត្ររដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋនៅក្នុងសហគមន៍ ក្នុងតំបន់ជាច់ស្រយាលនៃខេត្តពាយព្យក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩០ មកដល់បច្ចុប្បន្ន។ អង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ បាននិងកំពុងអនុវត្តន៍កម្មវិធីលើវិស័យ ៥ ក្នុងខេត្តគោលដៅទាំង ៧ នៃភូមិភាគពាយព្យ ក្នុងប្រទេសកម្ពុជាដែលក្នុងនោះមានប្រជាពលរដ្ឋក្នុងសហគមន៍ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ សហការគ្នាបានយ៉ាងល្អ ដើម្បីធ្វើឲ្យប្រសើរឡើងដល់ជីវៈភាពរស់នៅរបស់ប្រជាពលរដ្ឋ ឈានទៅរកការកាត់បន្ថយភាពក្រីក្រ ស្របទៅនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្នុងឆ្នាំ២០១៨នេះ អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ បានសម្រេចកិច្ចការជាច្រើនស្របទៅតាមផែនការយុទ្ធសាស្ត្រទាំង ៥វិស័យ រួមមានៈ វិស័យសេដ្ឋកិច្ច អភិបាលកិច្ច សុខភាព អភិវឌ្ឍន៍សហគមន៍ និងវិស័យអប់រំ។ ក្រៅពីនោះ ពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ បានធ្វើការងារមនុស្សធម៌ជាច្រើន ក្នុងការលើកកម្ពស់សុខភាព អប់រំ និងការផ្តល់ជំនួយផ្សេងៗដល់ប្រជាពលរដ្ឋផ្ទុក និងអ្នករស់នៅជាមួយមេរោគអេដស៍ ចំនួន ៤៨០០នាក់ ក្នុងខេត្តបាត់ដំបង និងបានផ្តល់អាហារូបករណ៍ដល់កុមារក្រីក្រចំនួន ២៦៩នាក់ក្នុងខេត្តបាត់ដំបង ប៉ៃលិន សៀមរាប និងកំពង់ធំ ដើម្បីឲ្យកុមារទាំងនោះបានចូលរៀនបន្តនៅថ្នាក់សកលវិទ្យាល័យ។ សម្រាប់ឆ្នាំសិក្សា ២០១៧ ២០១៨នេះ មាននិស្សិតដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិចំនួន ៣៦នាក់ ក្នុងចំណោមសិស្ស ៣៨នាក់ និង ១៥នាក់ ក្នុងចំណោមសិស្ស ២១នាក់ ដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ។

លើវិស័យអភិបាលកិច្ចមូលដ្ឋាន អង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ បានបណ្តុះបណ្តាលសិស្សនិស្សិត គរុសិស្ស និងសមណៈសិស្សចំនួន ១៦១០រូប ក្នុងនោះមានស្ត្រីចំនួន ៥៦% ផងដែរ។ ក្រៅពីនោះ អង្គការបានសហការជាមួយមន្ទីរអប់រំយុវជន និងកីឡាខេត្ត ធ្វើការបណ្តុះបណ្តាលគ្រូវិទ្យាល័យ បានចំនួន១៨៥នាក់ មាន ៥៤%ជាស្ត្រី អំពីវិស័យអប់រំសីលធម៌ពលរដ្ឋវិជ្ជា ដែលជាមូលដ្ឋានគ្រឹះនៃការអប់រំ។

ជោគជ័យដ៏ធំធេងទាំងនេះ បានមកពីការខិតខំប្រឹងប្រែង យោគយល់ ពីសំណាក់បុគ្គលិក អាជ្ញាធរ មូលដ្ឋានពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋមូលដ្ឋាន សិស្សនិសិត្ស លោកគ្រូអ្នកគ្រូ វិទ្យាល័យ សកលវិទ្យាល័យ គរុសិស្ស និងសាមណៈសិស្ស ដែលបានគាំទ្រ និងចូលរួមយ៉ាងសកម្មជាមួយ អង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍។

ក្នុងនាមឲ្យអង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ ខ្ញុំព្រះករុណាខ្ញុំសូមឧទ្ទិសនូវសមិទ្ធផលទាំងនេះ ចែកជូនដល់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ជាប្រយោជន៍ និងជាសេចក្តីសុខជានិរន្តរ៍តទៅ។

សូមអរព្រះគុណ និងអរគុណ។

ធម្មបណ្ឌិត ហេង មណីចិន្តា

នាយកប្រតិបត្តិពដអ

# មាតិកា


សាររបស់នាយកប្រតិបត្តិពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ -------------------- ២

អំពីពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ -------------------- ៤

សកម្មភាព ឆ្នាំ ២០១៨ -------------------- ៥

- អភិវឌ្ឍន៍សហគមន៍កសិកម្ម -------------------- ៥
- លើកស្ទួយអភិបាលកិច្ចមូលដ្ឋាន -------------------- ៦
- លើកស្ទួយសុខភាពអ្នកផ្ទុកមេរោគអេដស៍ -------------------- ៧
- លើកស្ទួយវិស័យសិក្សាតាមជនបទ -------------------- ៩
- ពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម -------------------- ១០
- ផែនការឆ្នាំ ២០១៩ -------------------- ១០

ផ្នែកហិរញ្ញវត្ថុ -------------------- ១១

គណកម្មាធិការបរធនបាល -------------------- ១៤

ទីតាំងការិយាល័យពដអក្នយងខេត្តទាំង៧ -------------------- ១៥

# អំពី ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍

ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលមានបុគ្គលិកខ្មែរបំរើការងារចំនួន ៥៧នាក់ ក្នុងខេត្តគោលដៅចំនួន៧ នៃភូមិភាគពាយព្យក្នុងប្រទេសកម្ពុជា ។ ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ លើកកំពស់ការគោរពសិទ្ធិមនុស្ស ការអប់រំតាមបែបប្រជាធិបតេយ្យ ដូចជាការគ្រប់គ្រងសហគមន៍ ហើយនិងធានាថាសុខភាពនិង វិស័យអប់រំនៅជនបទមានភាពល្អប្រសើរឡើង ។

## ទស្សនវិស័យ

អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ចង់ឃើញនូវ សង្គមប្រជាធិបតេយ្យមានការអប់រំល្អមួយ ដែលគ្មានភាពក្រីក្រ និងភាពគ្មានជម្ងឺ ដែលអាចការពារបាន មានការគោរពច្បាប់និងគោរពសិទ្ធិមនុស្ស ជាសង្គមសីលធម៌ មួយដែលបដិបត្តិតាមពុទ្ធឱវាទនិងទំនៀមទម្លាប់វប្បធម៌ប្រពៃណីខ្មែរ និង ជាសង្គមមួយដែលមានមនសិការចំពោះបរិដ្ឋាននិងយល់ដឹងពីជំរើសដែលបង្ហាញតាមរយៈការអភិវឌ្ឍន៍និងសាកលភាវូបនីយកម្ម

## ភារៈប្រកាស

អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ លើកទឹកចិត្ត ផ្តល់យោបល់ និងផ្តល់សេវាកម្ម គាំទ្រនិងបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋកម្ពុជាដើម្បីចូលរួមការអភិវឌ្ឍន៍ សង្គមសេដ្ឋកិច្ចប្រកបដោយនិរន្តរ៍ភាពនៅក្នុងសហគមន៍។

## ទស្សនវិជ្ជា

អង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ មានបំណងប្រាថ្នារួមចំណែកជាមួយ រាជរដ្ឋាភិបាលកម្ពុជាជួយឲ្យសំរេចបាននូវការលូតលាស់ និងអភិវឌ្ឍន៍របស់ប្រជាពលរដ្ឋ។ ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ ប្រកាន់យក គោលការណ៍ពុទ្ធសាសនាជាមគ្គុទេសន៍សំរាប់ការអភិវឌ្ឍន៍ប្រកបដោយការចូលរួមពីសហគមន៍ និងនាំមកនូវលទ្ធផលដែលជាគោលការគ្រឹះនៅថ្នាក់មូលដ្ឋាន។ ការផ្សារភ្ជាប់ពុទ្ធសាសនាទៅនឹងសង្គមគឺជាគោលបំណងដ៏សំខាន់មួយ ដែលចូលរួមសហការដោយព្រះសង្ឃនិងពុទ្ធបរិស័ទ ក្នុងការអនុវត្តសកម្មភាព ដើម្បីផ្តល់នូវការសង្គ្រោះនិងសេវាសង្គមនៅក្នុងសហគមន៍។

គំរោងកម្មវិធីទាំងអស់ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ក្រុមគោលដៅទាំងអស់ ក្នុងគោលបំណងសម្រេចឲ្យបាននូវភាពចុះសម្រុងគ្នារវាងឯកត្តបុគ្គល សង្គម និងបរិយាកាសតាមផ្លូវព្រះធម៌។ គំរោងកម្មវិធីផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចសង្គម សុខមាលភាព ផ្លូវចិត្ត និងសតិបញ្ញាដល់ក្រុមគោលដៅ និងដឹកនាំពួកគាត់ទាំងអស់នោះដោយសន្សឹមៗដើម្បីឆ្ពោះទៅរកការជឿជាក់ និងពឹងពាក់លើសមត្ថភាពខ្លួនឯង។

# សកម្មភាពឆ្នាំ ២០១៨

## I. អភិវឌ្ឍន៍សហគមន៍កសិកម្ម

ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ ក្នុងភាពជាដៃគូជាមួយ សហពន្ធ័សហករណ៍ អាល្លឺម៉ង់ បានផ្តល់ការគាំទ្រសហគមន៍កសិកម្មចំនួន ៩២ ក្នុងខេត្តគោលដៅទាំង ៧ ។ ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ បានផ្តោតលើការពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកគណកម្មាធិការត្រួតពិនិត្យសហគមន៍មានស្រាប់ និងការការបណ្តុះបណ្តាលសមត្ថភាពសមាជិកសហគមន៍កសិកម្ម នៅតាមខេត្តដាច់ស្រយាល នៃប្រទេសកម្ពុជា តាមរយៈការផ្តល់ និងសម្របសម្រួល ផ្នែកហិរញ្ញវត្ថុ ទុនជាថវិកា និង បង្កើតជាបណ្តាញអោយបំពេញការងារ ។

### ក) ការបណ្តុះបណ្តាល

អង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ បានបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពទៅលើប្រធានបទផ្សេងៗជាច្រើន ដើម្បីបង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាផ្តល់យោបល់ បេឡាករ គណនេយ្យ ហេរញ្ញិក និងសមាជីកក្រុមប្រឹក្សានាយកស្តីពីរបាយការណ៍ហិរញ្ញវត្ថុតាមបែបទម្រង់ថ្មី និងការរៀបចំរបាយការណ៍ចំណូល ឲ្យស្របទៅនឹងទម្រង់ថ្មីរបស់នាយកដ្ឋានផ្សព្វផ្សាយសហគមន៍កសិកម្ម។ វគ្គបណ្តុះបណ្តាលចំនួន៣០ ដោយមានអ្នកចូលរួមមកពីសហគមន៍កសិកម្មចំនួន៩២ និងអ្នកចូលរួមសារុបចំនួន ១១៩០នាក់។

- ✓ វគ្គបណ្តុះបណ្តាល ស្តីពីរបៀបធ្វើបញ្ជីតុល្យភាព
- ✓ វគ្គបណ្តុះបណ្តាល ស្តីពីបទបញ្ញត្តផ្ទៃក្នុងសម្រាប់សកម្មភាពឥណទានរបស់សហគមន៍ដល់សមាជិក
- ✓ វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងសហគមន៍កសិកម្ម
- ✓ វគ្គបណ្តុះបណ្តាល ស្តីពី របៀបធ្វើរបាយការណ៍ប្រចាំឆ្នាំ
- ✓ វគ្គបណ្តុះបណ្តាល ស្តីពីការកសាងផែនការមុខរបរ
- ✓ សិក្ខាសាលាថ្នាក់ដំបន់ស្តីពី ការផ្សាភ្ជាប់សហគមន៍ទៅនឹងទីផ្សាក្រុមហ៊ុនឯកជន

### ខ) ការចុះសម្របសម្រួល និងណែនាំ សហគមន៍

ដើម្បីពង្រឹង និងសម្របសម្រួល ដល់ការងារសហគមន៍ឲ្យកាន់តែមានប្រសិទ្ធិភាពជារៀងរាល់ខែ បុគ្គលិក ពដអ បានចុះដល់សហគមន៍មូលដ្ឋាន ដើម្បីតាមដាន ណែនាំ និងពង្រឹងសមត្ថភាពសហគមន៍ ឆ្លើយតបទៅនឹងតម្រូវការពួកគាត់។

- ការចុះសម្របសម្រួល និងណែនាំ សហគមន៍ចំនួន៩២ សហគមន៍ ដោយមានអ្នកដែលបានទទួលផលប្រយោជន៍ពីការចុះនេះចំនួន ៦៧៣ នាក់
- ការចុះវាយតម្លៃសហគមន៍ ទាំង ១០៩ ដែលជាលទ្ធផល នៅមានសហគមន៍ដែលសកម្មចំនួន ៩២

### គ) ទស្សនៈកិច្ចសិក្សា

មានសមាជិកសហគមន៍កសិកម្មចំនួន ៧០នាក់ តំណាងឲ្យ ២៣សហគមន៍ ត្រូវបានអញ្ជើញឲ្យទៅទស្សនៈកិច្ចសិក្សា ដកស្រង់បទពិសោធន៍ផ្នែកការដាំដុះបន្លែសរីរាង្គ នៅរមណីយដ្ឋានភី ពិកនិក ខេត្តព្រះសីហនុ។ មានសមាជិកចំនួន ៦៣នាក់ ដែលជាកសិករ តំណាងឲ្យ ២៣សហគមន៍កសិកម្ម បានរៀបចំអតីតក្រុមសាលាស្រែ និងបានជ្រើសរើសស្រែបង្ហាញ ដើម្បីចុះកិច្ចសន្យាដាំបន្លែសម្រាប់ឆ្នាំ ២០១៩ជាមួយ EAC/KOC។

## II. លើកស្ទួយអភិបាលកិច្ចមូលដ្ឋាន

កម្មវិធីអភិបាលកិច្ចមូលដ្ឋាន មានគោលបំណងធ្វើឲ្យប្រសើរឡើងដល់អភិបាលកិច្ចមូលដ្ឋាន បង្កើនការចូលរួម និងផ្សារភ្ជាប់ពលរដ្ឋទៅនឹងកិច្ចការរដ្ឋបាលមូលដ្ឋាន ពិសេសយុវជនក្នុងសហគមន៍។ ពដអ ផ្តល់ការបណ្តុះបណ្តាលសមត្ថភាព និងការផ្សារភ្ជាប់ជាមួយសហគមន៍ដើម្បីអប់រំអ្នកចូលរួមពីតួនាទី និងការទទួលខុសត្រូវ និងយន្តការអភិវឌ្ឍន៍ សំរាប់ការសន្ទនាដើម្បីកសាងនូវភាពជឿជាក់ និងតម្លាភាពនៅក្នុងដំណើរការអភិបាលកិច្ច។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ អង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ រៀបចំកម្មវិធីមួយចំនួនដូចខាងក្រោមៈ

### ក) ការអប់រំភាពជាពលរដ្ឋប្រជាធិបតេយ្យ ដល់លោកគ្រូ អ្នកគ្រូវិទ្យាល័យ

បង្កើនការយល់ដឹងអំពីការអប់រំមេរៀនអាទិភាពក្នុងមុខវិជ្ជាសីលធម៌ ពលរដ្ឋវិជ្ជា ក្នុងបរិបទគោលការណ៍អប់រំកម្ពុជា និង ក្នុងបរិបទការអប់រំភាពជាពលរដ្ឋប្រជាធិបតេយ្យ ដល់លោកគ្រូ អ្នកគ្រូនៃវិទ្យាល័យមោងឬស្សី វិទ្យាល័យសម្តេចឪ និង វិទ្យាល័យបវេល ក្នុងខេត្តបាត់ដំបង ដែលស្ថិតក្នុងគម្រោងសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា និងមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ ឲ្យក្លាយទៅជាគ្រូបង្គោលយ៉ាងមានសមត្ថភាព ក្នុងការបង្រៀនមុខវិជ្ជានេះ។

សិក្ខាសាលានេះបានរៀបចំជាពីរលើកៈ លើកទីមួយរៀបចំឡើងនៅខេត្តសៀមរាបកាលពីថ្ងៃទី ១៩ ដល់២១ ខែតុលាឆ្នាំ ២០១៨ ស្តីពី សីលធម៌ពលរដ្ឋវិជ្ជា មានអ្នកចូលរួមចំនួន ៣១នាក់ ក្នុងនោះ មានស្ត្រីចំនួន ១៩នាក់។ ពួកគាត់គឺជាគ្រូឯកទេសមុខវិជ្ជាសីលធម៌ពលរដ្ឋវិជ្ជា ថ្នាក់ទី ១០ដល់១២មកពីវិទ្យាល័យ ៩ក្នុងខេត្តសាកល្បងចំនួន ៣។

សិក្ខាសាលាលើកទី ២ ស្តីពី សីលធម៌ពលរដ្ឋវិជ្ជា នៅតាមសាលាទាំង៩សាលាផ្ទាល់តែម្តង ដែលមានអ្នកចូលរួមចំនួន ១៨៥នាក់ ក្នុងនោះមាន ១០១នាក់ជាស្ត្រី។

### ខ) វគ្គផ្សព្វផ្សាយ ពលរដ្ឋវិជ្ជា ដល់និស្សិតសាកលវិទ្យាល័យ និងគរុសិស្ស

កម្មវិធីនេះ ត្រូវបានរៀបចំការផ្សព្វផ្សាយជា ៣ស៊េរី ។ ប្រធានបទស៊េរី ១ស្តីពី ការណែនាំអំពីការអប់រំពលរដ្ឋវិជ្ជា។ ស៊េរី ២ ស្តីពី គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ឯស៊េរី ៣ស្តីពី អំណាចធំៗទាំងបី ក្នុងលទ្ធិប្រជាធិបតេយ្យ។ ក្នុងស៊េរីនីមួយៗមានរយៈពេលផ្សព្វផ្សាយ៤ម៉ោង និងមានប្រធានបទផ្សេងៗពីគ្នា។

ក្នុងឆ្នាំ២០១៨នេះ បានអនុវត្តន៍ក្នុងខេត្តគោលដៅចំនួន ៥ រួមមាន បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ និងខេត្តព្រះវិហារ សរុបមានសិស្សានុសិស្សចំនួន ១៦១០នាក់ ក្នុងនោះមានសិស្សស្រីចំនួន ៩០៥នាក់=៥៦% បានចូលរួមវគ្គផ្សព្វផ្សាយចប់ទាំង៣ស៊េរី។

## គ) អាសាស្ម័គ្រ

នេះជាកម្មវិធីបណ្តុះបណ្តាលយុវជនទាំងកំពុងសិក្សាក្នុងវិទ្យាល័យ សាកលវិទ្យាល័យ និងយុវជននានា ដែលមិនមានការធ្វើមកចូលរួមដោយស្ម័គ្រចិត្ត។ វគ្គបណ្តុះបណ្តាលនេះ ចែកចេញជា ២ដំណាក់កាលៈ

១. ការចូលរួមវគ្គបណ្តុះបណ្តាលទ្រឹស្តី រយៈ៦ថ្ងៃ ស្តីពីយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

២. ការចុះហាត់ការជាមួយថ្នាក់រដ្ឋបាលក្រោមជាតិ រួមមានឃុំ/សង្កាត់ ស្រុក/ក្រុង និងការិយាល័យនានាក្នុងខេត្តរយៈពេល ៦ខែក្រោយពីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ដើម្បីរៀនយកបទពិសោធន៍ផង និងបានអនុវត្តការងារតាមសមត្ថភាពផងដែរ។

កម្មវិធីនេះ បាននិងកំពុងអនុវត្តន៍ក្នុងខេត្តចំនួន ៣ គឺ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តកំពង់ធំ។

ក្នុងឆ្នាំ២០១៨នេះមាននិស្សិតចូលរួមវគ្គបណ្តុះបណ្តាលទាំងបីខេត្តចំនួន ១៥០នាក់ក្នុងនោះមានសិស្សស្រី ១០៤នាក់ (៦៩%)។ ចំណែកអ្នកចុះហាត់ការស្ម័គ្រមានចំនួន ១១០នាក់ ក្នុងនោះមានអ្នកហាត់ការជាស្រីចំនួន ៧១នាក់ (៦៥.%) ដែលបានហាត់ការនៅក្នុង ៣ខេត្ត ៣ក្រុង ៥ស្រុក ៧សង្កាត់ និង៨ឃុំ។

# III. លើកស្ទួយសុខភាពអ្នកផ្ទុកមេរោគអេដស៍

កម្មវិធីនេះ ធ្វើឡើងក្នុងគោលដៅលុបបំបាត់ការឆ្លងរីករាលដាល មេរោគអេដស៍ និងការស្លាប់ដោយសារ ជម្ងឺអេដស៍ នៅឆ្នាំ២០២៥។ ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ពដអ បានអនុវត្តកម្មវិធីនៅក្នុងស្រុកប្រតិបត្តិ៥ គឺស្រុកប្រតិបត្តិបាត់ដំបងមាន២៣មណ្ឌលសុខភាព ស្រុកប្រតិបត្តិសង្កែមាន១៥មណ្ឌលសុខភាព ស្រុកប្រតិបត្តិមោងឫស្សី ១៣មណ្ឌលសុខភាព ស្រុកប្រតិបត្តិថ្មគោលចំនួន១៨ មណ្ឌលសុខភាព និងស្រុកប្រតិបត្តិសំពៅលូនចំនួន ១០មណ្ឌលសុខភាព និងមាន១មន្ទីរពេទ្យ(មន្ទីរពេទ្យយោធភូមិភាគទី៥ ឬ ៣២)។ សរុបមានចំនួន ៧៩មណ្ឌលសុខភាព ក្នុងខេត្តបាត់ដំបង។

អ្នកជំងឺសរុបទាំង៥ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យយោធភូមិភាគទី០៥ (៣២) ដែលបានទទួលការថែទាំពី ពដអ នៅក្នុងឆ្នាំ ២០១៨ មានចំនួន ៥២៩៣នាក់ ក្នុងនោះស្ត្រី១០៥៩នាក់។ ក្នុងឆ្នាំនេះ មានអ្នកទទួលមរណភាពដែលបង្កដោយមេរោគអេដស៍ មានចំនួន១៧នាក់ (ស្រី១៤នាក់) និង អ្នកដែលផ្លាស់ប្តូរទីលំនៅចំនួន ១៤នាក់។

ស្ថិតិអ្នកជម្ងឺកំពុងទទួលសេវាពី ពដអ ឆ្នាំ២០១៨ៈ

- អ្នកជម្ងឺស្នាក់ក្នុងស្រុកប្រតិបត្តិមោងឫស្សីចំនួន ៦៨៤នាក់ (ស្រ្តី៣៧១នាក់)
- អ្នកជម្ងឺស្នាក់នៅក្នុងស្រុកប្រតិបត្តិសង្កែចំនួន ២៦៤នាក់ (ស្រ្តី១៦៤)
- អ្នកជម្ងឺស្នាក់នៅក្នុងស្រុកប្រតិបត្តិបាត់ដំបងចំនួន ២៥៧២នាក់ (ស្រ្តី១៤០៤នាក់)
- អ្នកជម្ងឺស្នាក់នៅក្នុងស្រុកប្រតិបត្តិថ្មគោល ចំនួន ៧៨៩នាក់ (ស្រ្តី៤២៨នាក់)
- អ្នកជម្ងឺស្នាក់នៅក្នុងស្រុកប្រតិបត្តិសំពៅលូន ចំនួន ៥១៩នាក់ (ស្រ្តី២៩១នាក់)
- អ្នកជម្ងឺស្នាក់នៅក្នុងមន្ទីរពេទ្យយោធភូមិភាគ ចំនួន ២០៦នាក់ (ស្រ្តី៦៨នាក់)

សកម្មភាពដែលសំខាន់របស់កម្មវិធីនេះ គឺ

## ក) ការស្វែងរកអ្នកជំងឺដែលឆ្លងមេរោគថ្មី

ក្នុងឆ្នាំ ២០១៨ នេះ មានអ្នកជំងឺថ្មី ដែលបានរកឃើញដោយ ពដអ ក្នុងស្រុកទាំង១៤នៃខេត្តបាត់ដំបង ចំនួន ១៨៩នាក់ ដែលក្នុងនោះ ជាស្រ្តីចំនួន៧៨នាក់។ ក្នុងចំនួននេះ មានអ្នកដែលដឹងខ្លួនថាមានជំងឺអេដស៍ តែបដិសេធមិនទទួលសេវាពី ពដអ ចំនួន ២៩នាក់ (១៥%) ដែលក្នុងនោះ ស្រ្តីមានចំនួនដល់ទៅ ៣៨% នៃអ្នកដែលបដិសេធមិនទទួលសេវា។

## ខ) ការផ្តល់ការប្រឹក្សានិងគាំទ្រដល់អ្នកជំងឺ

- ផ្តល់ប្រឹក្សាដល់អ្នកជំងឺទាំងអស់អំពីសារៈសំខាន់នៃថ្នាំពន្យារជីវិត (ARV) និងរបៀបប្រើដែលត្រឹមត្រូវជាប់លាប់របស់ថ្នាំពន្យារនេះ
- ផ្តល់ប្រឹក្សាលើការថៃទាំសុខភាពអោយបានល្អដើម្បីទប់ទល់ជាមួយជំងឺឱកាសនិយម
- ផ្តល់ប្រឹក្សាដល់អ្នកជំងឺដែលទើបរកឃើញថ្មី និង បន្តរុករកដល់ដៃគូដែលសង្ស័យថាអាចមានផ្ទុកមេរោគអេដស៍ដែរ
- ផ្តល់ការគាំទ្រថវិកាដល់អ្នកជំងឺ២០%ដែលគ្មានលទ្ធភាពក្នុងការទទួលសេវាពីសេវាសុខភាពរដ្ឋ
- ផ្តល់ការប្រឹក្សានិងគាំទ្រជាពិសេសដល់យុវជនក្នុងរវាងអាយុ១៥-១៩ ឆ្នាំ ដែលផ្ទុកមេរោគអេដស៍
- ផ្តល់ប្រឹក្សានិងគាំទ្រជាពិសេសដល់ស្រ្តីមានផ្ទៃពោះ អោយទៅទទួលសេវាពិគ្រោះសុខភាពមុនសម្រាលបុត្រ ក្រែងមានផ្ទុកមេរោគអេដស៍

## គ) ការផ្តល់ជំនួយបន្ទាន់

ក្រោមជំនួយឧបត្ថម្ភពីសប្បុរសជននានានៅក្រុង Lowell សហរដ្ឋអាមេរិក អ្នកជំងឺដែលនៅក្នុងឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង បានទទួលនូវជំនួយអាហារូបត្ថម្ភចំនួន ២១០គ្រួសារ ផងដែរ។

## IV. លើកស្ទួយវិស័យសិក្សាតាមជនបទ

### ក) កម្មវិធីអាហារូបករណ៍ដល់សិស្សក្រីក្រ

កម្មវិធីនេះ ពដអបានយកចិត្តទុកដាក់លើការសិស្សក្រីក្រ និងបានផ្តល់ការគាំទ្រដល់កុមារក្រីក្រ ដែលគ្មានលទ្ធភាពទៅរៀន ក្នុងខេត្ត៤ គឺខេត្តបាត់ដំបង ប៉ៃលិន សៀមរាប និងខេត្តកំពុងធំ នូវឱកាសរៀនសូត្រ ចាប់តាំងពីបឋម រហូតដល់ឧត្តមសិក្សា។ ពដអ បានស្វែងរកឪពុកម្តាយធម៌នៅបរទេស ជួយឧបត្ថម្ភលើផ្នែកសម្ភារៈសិក្សា ថវិកាសម្រាប់ទៅសាលារៀន។

ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ពដអ មាន៖

- កុមារនិងយុវជនដែលទទួលអាហារូបករណ៍ចំនួន២៥៨នាក់ (ស្រី១៦៥នាក់) តាមរយៈអង្គការកុមារមេគង្គប្រទេសបារាំង។
    - បឋមសិក្សា ៣៤នាក់
    - មធ្យមកំរិត១ ៨៧ នាក់
    - មធ្យមកំរិត២ ៨៣ នាក់
    - សាកលវិទ្យាល័យ ៣០នាក់
    - សាលាវិជ្ជាជីវៈ ២៤នាក់

- កុមារដែលទទួលអាហារូបករណ៍ចំនួន២០នាក់ (ស្រីនាក់) តាមរយៈអង្គការមូលនិធិភាពញញឹមនៃកុមារអាស៊ី (ASEF) និងសប្បុរសជនអូស្ត្រាលី
    - បឋមសិក្សា ១៩នាក់
    - មធ្យមកំរិត១ ០៦ នាក់

**លទ្ធផលដែលទទួលបានក្នុងវិស័យអប់រំ**

- លទ្ធផលប្រឡងឆ្នាំសិក្សា ២០១៧-២០១៨
    - ✓ ប្រឡងឌីប្លូមចំនួន៣៨នាក់ ជាប់ចំនួន ៣៦នាក់ (៩៥%)
    - ✓ ប្រឡងបាក់ឌុបចំនួន២១នាក់ ជាប់ចំនួន១៥នាក់ (៧១%)
- ការទទួលបានការងារ
    - ✓ ប្រឡងជាប់ជាគរុសិស្សមត្តេយ្យសាលារដ្ឋ ១ នាក់
    - ✓ ជាប់បរិញ្ញាបត្រ ហើយមានការងារធ្វើ ១១ នាក់
    - ✓ ជាប់សាលាវិជ្ជាជីវៈ ហើយមានការងារធ្វើ ៨ នាក់

### ខ) ការផ្តល់ជំនួយឧបត្ថម្ភ ដល់សិស្សខ្វះខាតខ្លាំង

- ✓ ចែកស្បៀងជាអាហារូបត្ថម្ភដល់សិស្សខ្វះខាតចំនួន ១២០ នាក់
  - បាត់ដំបង ៣០នាក់
  - ប៉ៃលិន ៤០ នាក់
  - ព្រះវិហារ ៥០នាក់
- ✓ ចែកកង់ដល់សិស្សដែលនៅឆ្ងាយពីសាលារៀនចំនួន ១០០ នាក់នៅបាត់ដំបង

## V. ពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម

ជារៀងរាល់ឆ្នាំ ពដអ បានរៀបចំសិក្ខាសាលា ស្តីពីពុទ្ធសាសនាផ្សារភ្ជាប់សង្គម តាមរយៈ វិទ្យុសហគមន៍គាំទ្រដោយព្រះសង្ឃនិងពុទ្ធបរិស័ទ។ ពដអ បាននិមន្តព្រះសង្ឃដែលមានកម្មវិធីផ្សព្វផ្សាយការអប់រំសីលធម៌និងផ្លូវចិត្តតាមបែបព្រះពុទ្ធសាសនាដល់ពុទ្ធបរិស័ទ្ធនិងមន្ត្រីពាក់ព័ន្ធមួយចំនួនមកចូលរួម និងចែករំលែកយោបល់គ្នាទៅវិញទៅមក ដើម្បីបង្កើនការចូលរួមក្នុងការអភិវឌ្ឍសង្គមរបស់ពុទ្ធសាសនា អោយកាន់តែមានភាពល្អប្រសើរឡើង។

ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ផែនការអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ក៏ដូចជារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ២០១៨នេះ ពដអ បានលើកយកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Social Development Goals = SDGs) មកធ្វើជាប្រធានបទក្នុងសិក្ខាសាលាលើកនេះ ដោយដាក់ឈ្មោះថា "ពុទ្ធសាសនានឹងគោលដៅសាកលសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព"។ គោលដៅទាំងនេះ ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ ហើយត្រូវបានផ្សព្វផ្សាយជាគោលដៅសាកលសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គោលដៅទាំងនេះ បានជំនួស គោលដៅអភិវឌ្ឍន៍សហស្សវត្សដែលបានផុតកំណត់នៅចុងឆ្នាំ ២០១៥។

សិក្ខាសាលានេះ មានអ្នកចូលរួមចំនួន ១៥០នាក់/អង្គ ក្នុងនោះមាន ១១៣អង្គជាព្រះសង្ឃ ដែលនិមន្ត និង អញ្ជើញមកពីខេត្តចំនួន ៨ គឺ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ឧត្តមានជ័យ សៀមរាប ព្រះវិហារ កំពង់ធំ និងពោធិសាត់។ ក្នុងនេះមានកម្មវិធីវិទ្យុចំនួន ១៨ដែលបាន និងកំពុងផ្សព្វផ្សាយការអប់រំសីលធម៌សង្គមនិងការអប់រំចិត្តក្នុងខេត្តទាំងនោះ។ កម្មវិធីទាំង ១៨នេះ នឹងនាំយកលទ្ធផលសិក្ខាសាលា ទៅផ្សព្វផ្សាយ ជាពិសេស គឺផែនការអភិវឌ្ឍន៍សហប្រជាជាតិមកធ្វើការផ្សព្វផ្សាយផងដែរ។

## VI. ផែនការសម្រាប់ឆ្នាំ ២០១៩

សម្រាប់ឆ្នាំ ២០១៩ នេះ សកម្មភាពមានដូចគ្នានឹងក្នុងឆ្នាំ ២០១៨ ដែរ។ ពដអ នឹងប្រឹងប្រែងពង្រឹងគុណភាពសកម្មភាពទាំងឡាយអោយកាន់តែមានភាពប្រសើរឡើង

# ផ្នែកហិរញ្ញវត្ថុ

ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ គ្រប់គ្រងហិរញ្ញវត្ថុទៅតាមតម្រូវការរបស់ម្ចាស់ជំនួយ និងទទួលខុសត្រូវលើការគ្រប់គ្រងហិរញ្ញកិច្ចរបស់គម្រោងទាំងអស់ ដែលមាននៅ ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍។ ការិយាល័យហិរញ្ញវត្ថុនៅការិយាល័យកណ្តាល (លើកលែងតែគំរោងកម្មវិធីអេដស៍ ដែលផ្ញើពីម្ចាស់ជំនួយត្រង់ទៅសាខាបាត់ដំបងដែលអនុវត្តផ្ទាល់) ទទួលនូវកញ្ចប់ថវិកាពីម្ចាស់ជំនួយសម្រាប់សកម្មភាពទាំងអស់។ រាល់សកម្មភាពត្រូវបានអនុវត្តនៅតាមខេត្តគោលដៅ ហើយខេត្តនីមួយៗបានស្នើសុំថវិការអនុវត្តគម្រោង ពីការិយាល័យកណ្តាលសម្រាប់ការងារប្រចាំថ្ងៃ ហើយគណនេយ្យករទាំងនោះជាអ្នកស្នើសុំថវិកាទៅតាមខែនីមួយៗ។

សមតុល្យថវិកាចំណូលចំណាយក្នុងឆ្នាំថវិកា២០១៨ មានដូចក្នុងតារាងដែលភ្ជាប់មកជាមួយនេះ៖

១- តារាងសមតុល្យថវិកាឆ្នាំ២០១៨

២- តារាងចំណូលចំណាយសង្ខេបតាមម្ចាស់ជំនួយនីមួយៗ

៣- នាមម្ចាស់ជំនួយដែលផ្តល់ដល់ ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

១-តារាងសមតុល្យថវិកាឆ្នាំ២០១៨

| | | | | |
|---|---|---|---|---|
| ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ | | | | |
| សមតុល្យថវិកា | | | | |
| ប្រចាំឆ្នាំ ២០១៨ | | | | |
| របៈវេលានៃរបាយការណ៍ : ០១ មករា ដល់ ៣១ ធ្នូ ២០១៨ | | | | |
| I - | ក | សមតុល្យសល់ពី ២០១៧ | : | 53,000.10 |
| | ខ | ថវិកាទទួលបានឆ្នាំ២០១៨ | : | 405,129.90 |
| | គ | ចំណូលផ្សេងៗ | | 0.00 |
| | ឃ | ការប្រាក់ពីធនាគារ | : | 133.50 |
| | ង | ចំណូលសរុប | : | 458,263.50 |
| | ច | ចំណាយត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៨ | : | 443,796.82 |
| | ឆ | សមតុល្យ | : | 24,366.68 |
| II - | ក | គណនីសន្សំ | : | 17,248.30 |
| | ខ | គណនីចរន្ត | : | 3,903.77 |
| | គ | សាច់ប្រាក់ក្នុងដៃ ជាដុល្លារ | : | 194.91 |
| | ឃ | សាច់ប្រាក់ក្នុងដៃ ជារៀល | : | 112.03 |
| | ង | លុយមិនទាន់ទូទាត់ | | 0.00 |
| | ច | លុយត្រូវសង | | 817.00 |
| | ឆ | សមតុល្យប្រចាំឆ្នាំ | : | 24,366.68 |
| | ផ្ទៀងផ្ទាត់ដោយ………………… | | រៀបចំដោយ……………… | |
| | យឿន យត | | សុខ ភីម៉ា | |
| | ប្រធានគណនេយ្យ | | គណនេយ្យករ | |
| | យល់ព្រមដោយ……………… | | | |
| | ហេង មណីចិន្តា | | | |
| | នាយក | | | |

## ២- តារាងចំណូលចំណាយសង្ខេបតាមម្ចាស់ជំនួយនីមួយៗ

| | Donor | Balance Brought Forward from 2017 | Fund Received 2018 | Bank Interest | Total Revenue | Total Expense: as of December 2018 | Balance | % | Bank balance | | Cash On Hand | | Account Receiveable | Account Payable/Refund | Exchange Reconciliation | Balance |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | Saving Account | Current Account | Dollar | Riel/Dollar Equivalenc | | | | |
| 1 | Asian Child Shining Foundation | 0 | 2500 | - | 2,500.00 | 500 | 2,000.00 | | 2,000.00 | | | | | | | 2,000.00 |
| 2 | **CRS** | - | 75,903.55 | 27.31 | 75,930.86 | 72,931.84 | 2,999.02 | | 2,998.78 | - | 0.24 | | | | | 2,999.02 |
| 3 | CWS: Church World Service | 100.78 | - | (5.58) | 95.20 | 95.20 | - | | - | - | - | - | - | - | - | - |
| 4 | DGRV: German Cooperative and Raiffeisen Confederation – reg. assoc. | 17,790.15 | 166,938.04 | 37.03 | 184,765.22 | 184,537.50 | 227.72 | | $ 152.06 | 0.02 | 13.77 | 3.82 | - | - | 58.05 | 227.72 |
| 5 | **EDM: Enfants du Mekong** | 13,476.90 | 69,742.92 | 18.39 | 83,238.21 | 78,330.12 | 4,908.09 | | 97.17 | 3,903.75 | 52.25 | 34.92 | - | 820.00 | - | 4,908.09 |
| 6 | **KAS: Konrad Adenauer Stiftung** | 11,910.77 | 82,236.70 | 29.32 | 102,076.79 | 93,936.56 | 8,140.23 | | 7,912.92 | - | 127.71 | 73.03 | - | - | 26.57 | 8,140.23 |
| 7 | **KHANA** | - | 5,428.69 | 2.11 | 5,430.80 | 5,427.80 | 3.00 | | | | | | | (3.00) | | 3.00 |
| 8 | **Roka HIV/AIDS Relief** | 7,435.20 | 4,880.00 | 24.39 | 12,339.59 | 6,253.00 | 6,086.59 | | 6,086.54 | - | - | - | - | - | 0.05 | 6,086.59 |
| 9 | **Soul du Riz** | 2,286.30 | | 0.53 | 2,286.83 | 2,284.80 | 2.03 | | 0.83 | | 0.94 | 0.26 | | | | 2.03 |
| | សរុប | **53,000.10** | **405,129.90** | **133.50** | 458,263.50 | **443,796.82** | 24,366.68 | - | **17,248.30** | **3,903.77** | **194.91** | **112.03** | - | **817.00** | **84.67** | **24,366.68** |

## ៣-នាមម្ចាស់ជំនួយដែលផ្តល់ដល់ ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

| | ប្រភពទុន | លេខសៀវភៅធនាគារ | ឈ្មោះធនាគារ |
|---|---|---|---|
| 1 | Asian Child Shining Foundation | 002-2-00182-0-840 | CAMBDIAN COMMERCIAL BANK |
| 2 | CRS | 0300-02-393722-2-2 | ACLEDA Bank Plc. |
| 3 | CWS: Church World Service | 0300-02-292219-1-9 | ACLEDA Bank Plc. |
| 4 | DGRV: German Cooperative and Raiffeisen Confederation – reg. assoc. | 0040000017673 | ACLEDA Bank Plc. |
| 5 | EDM: Enfants du Mekong | 002-2-00069-6-840 | ACLEDA Bank Plc. |
| 6 | KAS: Konrad Adenauer Stiftung | 0300-02-257009-1-9 | ACLEDA Bank Plc. |
| 7 | KHANA | 0300-01-997074-1-4 | ACLEDA Bank Plc. |
| 8 | Roka HIV/AIDS Relief | 0300-01-220404-1-4 | ACLEDA Bank Plc. |
| 9 | Soul du Riz | 0300-02-210584-4-4 | ACLEDA Bank Plc. |
| | សរុប | | |

# គណៈកម្មាធិការបរធនបាល

គណៈម្មាធិការបរធនបាល គឺជាម្ចាស់វាសនាអនាគត នៃអង្គការមួយនេះ ក្នុងការធ្វើសេចក្តីសម្រេចលើបញ្ហាធំៗសំខាន់ៗ ដូចជា ការជ្រើសរើស តែងតាំង ឬផ្លាស់ប្តូរនាយក អនុម័តលើសំណើនានា ស្នើដោយនាយក ការរំលាយអង្គការ ។ល។ គណៈកម្មាធិការនេះ មានសមាជិកចំនួន ៥រូប ក្នុងនោះមានបុគ្គលិកអង្គការម្នាក់ ត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតពីបុគ្គលិកក្នុងសម័យមហាសន្និបាតអង្គការប្រចាំឆ្នាំ។ សមជិកបរធនបាលធ្វើការដោយស្ម័គ្រចិត្ត និងមិនគិតពីផលកម្រៃអ្វីទាំងអស់។ សមាជិកទាំង ៥រូប មានសមត្ថភាព និងជំនាញផ្សេងៗពីគ្នា ហើយត្រូវបានជ្រើសចេញពីស្ថាប័នផ្សេងពីគ្នា។

គណៈកម្មាធិការនេះ មានតួនាទីអ្នកផ្តល់ដំបូន្មានជាមនុស្សដែលមានចំណាប់អារម្មណ៍ដែលមានជំនាញសមត្ថភាពនិងចេតនាធ្វើការដើម្បីការរីកចម្រើននៃបេសកកម្មនិងគោលដៅរបស់ BFD ។ ពួកគេតំណាងឱ្យជំនាញនិងជំនាញដែលត្រូវការដើម្បីលើកកំពស់ការងាររបស់ក្រុមប្រឹក្សាភិបាលតាមរយៈគណៈកម្មាធិការ។ អ្នកផ្តល់ដំបូន្មានតំណាងឱ្យផ្នែកផ្សេងៗនៃជំនាញវិជ្ជាជីវៈហិរញ្ញវត្ថុអាជីវកម្មការគ្រប់គ្រងសេវាសង្គម ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ច។

សមាជិកភាព

| លរ | ឈ្មោះ | តួនាទី | កម្រិតវប្បធម៌ |
|---|---|---|---|
| ១ | លោក អ៊ុក វ៉ា | ប្រធានគណៈកម្មាធិការ | បរិញ្ញាបត្រជាន់ខ្ពស់ |
| ២ | លោកស្រី ហួត រតនៈ | ហិរញ្ញញិក | បរិញ្ញាបត្រជាន់ខ្ពស់ |
| ៣ | លោកស្រី ឡេង ឆេងលៀង | សមាជិកទទួលបន្ទុកការងារស្រ្តីនិងកុមារ | វេជ្ជបណ្ឌិត |
| ៤ | លោក ប៉ុញ ឧត្តម | សមាជិកទទួលបន្ទុកការងារបណ្តុះ បណ្តាល | បណ្ឌិតផ្នែកអភិវឌ្ឍន៍ជនបទ |
| ៥ | លោក យក់ ប៊ុនណា | តំណាងបុគ្គលិក ពដអ | ថៅកូវកម្មវិធី |

# ខេត្តគោលដៅសកម្មភាពរបស់ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

# ២០១៨

